**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១៤៦ . អនក្រ . បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៨.៨៤៦ ហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រ ស្រុករវៀង ខេត្តព្រះវិហារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ សាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៤៦ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច

យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## ស ម្រេ ច

**មាត្រា១: -**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ៨.៨៤៦( ប្រាំបីពាន់ប្រាំបីរយសែសិបប្រាំមួយ) ហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រ ឃុំរមទម ឃុំរបៀប ឃុំរស្មី និងឃុំរំដោះ ស្រុករវៀង ខេត្តព្រះវិហារ ដើម្បីធ្វើការវិនិយោគដាំដំណាំកសិ-ឧស្សាហកម្ម( កៅស៊ូ-អាកាស្យា) និងប្រភេទឈើផ្សេងទៀត ដូចមានក្នុងផែនទី និងនិយាមកាលេខ ៥២៧ចណលផ ចុះថ្ងៃទី ០២ ខែមិថុនា ឆ្នាំ២០១១ របស់សាលាខេត្តព្រះវិហារ ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា២: -**

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគ ដូចកំណត់ក្នុងមាត្រា១នៃអនុក្រឹត្យនេះ ត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់ និងគោលការណ៍របស់រាជរដ្ឋាភិបាល ។

**មាត្រា៣: -**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៤ -**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គ្រប់ក្រសួង ស្ថាប័ន និងអភិបាលនៃគណៈអភិបាលខេត្តព្រះវិហារ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ. កាលប្បវត្តិ

## ផែនទី បង្ហាញពីដីកាត់ចេញពីតំបន់ស្នើសុំសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន គីម ជាងួន ក្រុប ស្ថិតនៅក្នុងឃុំរមណីយ ឃុំកបប្រិប ឃុំស្វើ និងឃុំដោះ ស្រុកឆែប ខេត្តព្រះវិហារ




| ID | X | Y | ID | X | Y |
|---|---|---|---|---|---|
| 1 | 497516 | 1484485 | 12 | 502563 | 1487817 |
| 2 | 499091 | 1484485 | 13 | 502954 | 1487825 |
| 3 | 499082 | 1486215 | 14 | 502833 | 1490317 |
| 4 | 498098 | 1486203 | 15 | 503530 | 1481760 |
| 5 | 497433 | 1486197 | 16 | 504368 | 1481755 |
| 6 | 497345 | 1488024 | 17 | 504175 | 1481056 |
| 7 | 497991 | 1488097 | 18 | 503362 | 1480287 |
| 8 | 497329 | 1489611 | a | 502508 | 1480288 |
| 9 | 502399 | 1490363 | b | 502333 | 1480288 |
| 10 | 502330 | 1489250 | c | 503418 | 1481159 |
| 11 | 502340 | 1488174 | d | 502697 | 1481230 |

លេខ:.../០១១
បានឃើញ និង ឯកភាព
ស្វើ, ថ្ងៃទី...ខែ..6...ឆ្នាំ២០១១
មេឃុំស្វើ

សុខ_ឈុម

លេខ:156/11
បានឃើញ និង ឯកភាព
ឆែប, ថ្ងៃទី...ខែ06...ឆ្នាំ២០១១

លេខ:316/11
បានឃើញ និង ឯកភាព
មេឃុំ, ថ្ងៃទី...ខែ...ឆ្នាំ២០១១

លេខ:239/11
បានឃើញ និង ឯកភាព
ថ្ងៃទី...ខែ.06.ឆ្នាំ២០១១

គិត_ម៉ិច

លេខ:006/11
បានឃើញ និង ឯកភាព
ឆែប, ថ្ងៃទី.02.ខែ06..ឆ្នាំ២០១១
ប្រធានការិយាល័យរៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីស្រុកឆែប

លេខ:028...
បានឃើញ និង ឯកភាព
ឆែប, ថ្ងៃទី...ខែ06..ឆ្នាំ២០១១
ប្រធានការិយាល័យបរិស្ថានស្រុកឆែប

លេខ:253...
បានឃើញ និង ឯកភាព
ឆែប, ថ្ងៃទី.02.ខែ.06.ឆ្នាំ២០១១
អភិបាលស្រុកឆែប

ឯ_សារី

លេខ:155...
បានឃើញ និង ឯកភាព
ព្រះវិហារ, ថ្ងៃទី 02..ខែ.06...ឆ្នាំ២០១១

គិច.ឆ្លីដា

លេខ:180/2011
បានឃើញ និង ឯកភាព
ព្រះវិហារ, ថ្ងៃទី 02 ខែ 06 ឆ្នាំ២០១១

គង់_សោភ័ណ

លេខ:527...
បានឃើញ និង ឯកភាព
ព្រះវិហារ, ថ្ងៃទី02..ខែ06.ឆ្នាំ២០១១
អភិបាលខេត្ត

ស៊ុំ ម៉ារី